# ព្រះរាជក្រម

នស/រកម/០៦០៦/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី ២ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៧៥/០០៦/ ២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រាមួយ.-**

ត្រូវបានកែប្រែមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដូចខាងក្រោម :

**មាត្រា ១៣ថ្មី (ពីរ) .-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

- ឥស្សរជនខ្មែរមួយរូប ប្រធាន
- ឥស្សរជនខ្មែរមួយរូប អនុប្រធាន
- ឥស្សរជនខ្មែរប្រាំពីររូប សមាជិក

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំពីរ (៧) ខែ មុនថ្ងៃបោះឆ្នោត តាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

/.

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិចប្រាំបួន (៩) ខែ មុនថ្ងៃ បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិ ជ្រើសរើសបុគ្គលិកតាមការចាំបាច់សម្រាប់ដំណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

ចរស.០៦០៦.២៩៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ : ២៧២ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន